ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :..........០៩៥/១៤........ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសមន្ត្រី(ក្របខណ្ឌ)ថ្មី និងប្រឡងផ្ទៃក្នុង(ប្រឡងប្តូរក្របខ័ណ្ឌ) សម្រាប់ឆ្នាំ២០១៤

**យោង៖** លិខិតលេខ២២៤៥ មស.ក្រខ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់មហាជន សិស្ស-និស្សិត មន្ត្រីរាជការរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មេត្តាជ្រាបថា ក្នុងឆ្នាំ២០១៤នេះ ក្រសួងត្រូវការជ្រើសរើសៈ

១.មន្ត្រីថ្មី(ក្របខណ្ឌថ្មី) កម្រិតឧត្តម(ក្របខ័ណ្ឌប្រភេទ «ក»)...................... ចំនួន ៥៣នាក់

២.ប្រឡងផ្ទៃក្នុង(ប្រឡងប្តូរក្របខ័ណ្ឌ)..........................................................ចំនួន១២០កន្លែង

### I. អំពីការប្រឡងជ្រើសរើសមន្ត្រីថ្មី

#### ក.អង្គភាពដែលត្រូវជ្រើសរើស

| ល.រ | អង្គភាពជ្រើសរើស | ប្រភេទក្របខ័ណ្ឌ | ចំនួនជ្រើសរើស | ផ្សេងៗ |
|---|---|---|---|---|
| ១. | ទីស្តីការក្រសួង | ក | ១៦ | |
| ២ | មន្ទីររាជធានីភ្នំពេញ | ក | ២ | |
| ៣ | មន្ទីរ កប ខេត្ត កណ្តាល | ក | ២ | |
| ៤ | មន្ទីរ កប ខេត្ត ព្រៃវែង | ក | ១ | |
| ៥ | មន្ទីរ កប ខេត្ត ស្វាយរៀង | ក | ២ | |
| ៦ | មន្ទីរ កប ខេត្ត កំពង់ចាម | ក | ១ | |
| ៧ | មន្ទីរ កប ខេត្ត ត្បូងឃ្មុំ | ក | ២ | |
| ៨ | មន្ទីរ កប ខេត្ត ក្រចេះ | ក | ១ | |
| ៩ | មន្ទីរ កប ខេត្ត មណ្ឌលគិរី | ក | ១ | |
| ១០ | មន្ទីរ កប ខេត្ត រតនគិរី | ក | ១ | |
| ១១ | មន្ទីរ កប ខេត្ត ស្ទឹងត្រែង | ក | ១ | |
| ១២ | មន្ទីរ កប ខេត្ត កំពង់ធំ | ក | ១ | |

| | | | | |
|---|---|---|---|---|
| ១៣ | មន្ទីរ កប ខេត្ត ព្រះវិហារ | ក | ១ | |
| ១៤ | មន្ទីរ កប ខេត្ត សៀមរាប | ក | ១ | |
| ១៥ | មន្ទីរ កប ខេត្ត ឧត្តរមានជ័យ | ក | ១ | |
| ១៦ | មន្ទីរ កប ខេត្ត បន្ទាយមានជ័យ | ក | ២ | |
| ១៧ | មន្ទីរ កប ខេត្ត បាត់ដំបង | ក | ២ | |
| ១៨ | មន្ទីរ កប ខេត្ត ប៉ៃលិន | ក | ១ | |
| ១៩ | មន្ទីរ កប ខេត្ត ពោធិ៍សាត់ | ក | ២ | |
| ២០ | មន្ទីរ កប ខេត្ត កំពង់ឆ្នាំង | ក | ១ | |
| ២១ | មន្ទីរ កប ខេត្ត កំពង់ស្ពឺ | ក | ២ | |
| ២២ | មន្ទីរ កប ខេត្ត ព្រះសីហនុ | ក | ២ | |
| ២៣ | មន្ទីរ កប ខេត្ត កោះកុង | ក | ២ | |
| ២៤ | មន្ទីរ កប ខេត្ត កំពត | ក | ១ | |
| ២៥ | មន្ទីរ កប ខេត្ត កែប | ក | ២ | |
| ២៦ | មន្ទីរ កប ខេត្ត តាកែវ | ក | ២ | |
| | | សរុប | ៥៣នាក់ | |

**ខ-កម្រិតសញ្ញាបត្រ និងលក្ខខណ្ឌនៃការជ្រើសរើស**

- បេក្ខជនត្រូវមានអាយុច្រើនបំផុត៣០ឆ្នាំគិតមកដល់ថ្ងៃប្រឡង
- សញ្ញាបត្រយ៉ាងទាបបរិញ្ញាបត្រឬសញ្ញាបត្រសមមូល
- ផ្តល់អាទិភាពដោយបន្ថែមពិន្ទុលើមធ្យមភាគចុងក្រោយនៃពិន្ទុសរុប១០០% ចំពោះ ៖

+ជាជនពិការ(ដែលអាចបម្រើការងារបាន)បន្ថែម២ពិន្ទុ

+ស្ត្រីភេទ បន្ថែម២ពិន្ទុ

+មន្ត្រីជាប់កិច្ចសន្យានិងពលករអណ្តែត បន្ថែម៥ពិន្ទុ ។

ការបន្ថែមពិន្ទុនេះ ផ្តល់ជូនតែមួយប្រភេទក្នុងករណីដែលបេក្ខជនមានលក្ខណៈសម្បត្តិលើសពី១ ដោយយកលក្ខខ័ណ្ឌបន្ថែមពិន្ទុច្រើនជាងក្នុងចំណោមលក្ខខ័ណ្ឌដែលបេក្ខជនទទួលបាន ។

**គ-វិញ្ញាសា និងថេរវេលាប្រឡង**

-ភាសាអង់គ្លេស(QCM).............................................រយៈពេល ១ម៉ោង៣០នាទី (មេគុណ១)

- ចំណេះដឹងទូទៅពាក់ព័ន្ធ រដ្ឋបាល និងវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ.............................
.........................................................................រយៈពេល ២ម៉ោង០០នាទី (មេគុណ៣)

<u>បញ្ជាក់៖</u> បេក្ខជនទាំងពីរភេទ ត្រូវអនុវត្តតាមការកំណត់វិញ្ញាសាប្រឡងខាងលើ ដោយមិនអាចតវ៉ានៅពេលប្រឡង ដើម្បីឲ្យមានការកែសម្រួលតាមជំនាញខ្លួនឡើយ។

II. **អំពីការប្រឡងផ្ទៃក្នុង(ប្រឡងប្តូរប្រភេទក្របខ័ណ្ឌ)**

**ក.ចំណែងចែកប្រភេទក្របខ័ណ្ឌដែលត្រូវជ្រើសរើស**

១.ប្តូរចូលក្របខណ្ឌ «**ក**» នៃក្របខ័ណ្ឌគ្រូបង្រៀន....................ចំនួន៦០កន្លែង

២.ប្តូរចូលក្របខណ្ឌ «**ក**» នៃក្របខ័ណ្ឌបច្ចេកទេស..................ចំនួន៦០កន្លែង

**ខ- លក្ខខណ្ឌនៃការជ្រើសរើស**

- មន្ត្រីរាជការដែលមានសញ្ញាបត្រសមមូលនិងបរិញ្ញាបត្រ ឬមន្ត្រីរាជការដែលស្ថិតនៅយ៉ាងទាបបំផុតក្នុងថ្នាក់លេខ១១ ឋានន្តរស័ក្តិទី៣នៃក្របខណ្ឌប្រភេទ "ខ"
- មានអាយុយ៉ាងច្រើន៤៥ឆ្នាំគិតដល់ថ្ងៃប្រឡង

- បេក្ខជនត្រូវជាមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចំពោះបេក្ខជនប្រឡងប្តូរក្របខណ្ឌ"ក"នៃក្របខណ្ឌគ្រូបង្រៀនត្រូវមានក្របខណ្ឌគ្រូបង្រៀនតាំងពីមុនដាក់ពាក្យប្រឡង
- ផ្តល់អាទិភាពដោយបន្ថែមពិន្ទុលើមធ្យមភាគចុងក្រោយនៃពិន្ទុសរុប១០០% ចំពោះ ៖

+ស្ត្រីភេទ បន្ថែម២ពិន្ទុ

+ មន្ត្រីបម្រើការងារនៅតាមតំបន់ដាច់ស្រយាល បន្ថែម៣ពិន្ទុ

+មន្ត្រីដែលមានក្របខណ្ឌទាបជាងមុខតំណែង បន្ថែម៥ពិន្ទុ និង

+ជនពិការដោយគ្រោះថ្នាក់ការងារ ដោយមានការបញ្ជាក់ពីអង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងផ្ទាល់ បន្ថែម៥ពិន្ទុ ។

ការបន្ថែមពិន្ទុនេះ ផ្តល់ជូនតែមួយប្រភេទក្នុងករណីដែលបេក្ខជនមានលក្ខណៈសម្បត្តិលើសពី១ ដោយយកលក្ខខណ្ឌបន្ថែមពិន្ទុច្រើនជាងក្នុងចំណោមលក្ខខណ្ឌដែលបេក្ខជនទទួលបាន ។

**គ-វិញ្ញាសា និងថេរវេលាប្រឡង**

-លិខិតរដ្ឋបាល និងការដឹកនាំអង្គភាព............................រយៈពេល១ម៉៣០នាទី (មេគុណ២)

-ពាក់ព័ន្ធការងារ សមិទ្ធិផល និងផែនការរបស់ក្រសួង.......រយៈពេល២ម៉០០នាទី(មេគុណ១)

<u>បញ្ជាក់៖</u> បេក្ខជនទាំងពីរភេទ ត្រូវអនុវត្តតាមការកំណត់វិញ្ញាសាប្រឡងខាងលើ ដោយមិនអាចតវ៉ានៅពេលប្រឡង ដើម្បីឲ្យមានការកែសម្រួលតាមជំនាញខ្លួនឡើយ។

**III-សំណុំលិខិតចុះឈ្មោះប្រឡង**

- ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែមប្រៃសណីយ......................ចំនួន ០១ច្បាប់
- សេចក្តីចម្លង(ដោយសាលារាជធានី-ខេត្ត)សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(BacII) និងបរិញ្ញាប័ត្រ(បើមាន ចំពោះមន្ត្រីប្រឡងផ្ទៃក្នុង).....................ចំនួន ០១ច្បាប់
- ជីវប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦........................................ចំនួន ០១ច្បាប់
- សលាកបត្រឯកត្តជន.............................................................ចំនួន ០១ច្បាប់
- កិច្ចសន្យាបម្រើការងារក្រសួង.................................................ចំនួន ០១ច្បាប់
- បង្កាន់ដៃបង់សិទ្ធិប្រឡង.......................................................ចំនួន ០១ច្បាប់
- រូបថតថ្មី ៤x៦ ថតចំពីមុខគ្មានពាក់វ៉ែនតា ឬមួក...........................ចំនួន ០២សន្លឹក

*សម្រាប់មន្ត្រីថ្មី ស្នើបន្ថែមឯកសារ ៖*

- លិខិតបញ្ជាក់ទោស(ក្រោយពេលប្រឡងជាប់ជាស្ថាពរ)..................ចំនួន ០២ច្បាប់
- លិខិតពិនិត្យកាយសម្បទា(ក្រោយពេលប្រឡងជាប់ជាស្ថាពរ).........ចំនួន ០២ច្បាប់

*សម្រាប់បេក្ខជនប្រឡងប្តូរក្របខណ្ឌ ស្នើបន្ថែមឯកសារ៖*

- បញ្ជាក់ពី កន្លែងធ្វើការ មុខតំណែង(បើមាន)និងកាំប្រាក់ចុងក្រោយ..ចំនួន០១ច្បាប់

**កំណត់សំគាល់**

បេក្ខជនត្រូវសរសេរបំពេញពាក្យសុំប្រឡងដោយដៃ ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ និងមកដាក់ពាក្យដោយផ្ទាល់ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធច្បាប់ដើមដើម្បីបង្ហាញមន្ត្រីទទួលពាក្យ ដូចមានចែងក្នុងចំណុច "III" ។

**IV. អំពីកាលបរិច្ឆេទ**

**ក.លក់ពាក្យ ទទួលពាក្យ**

-លក់ពាក្យ និងទទួលពាក្យ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ

-ឈប់ទទួលពាក្យនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង៥ម៉០០ល្ងាច ជាកំហិត ។

**ខ.ប្រឡង**

-ការប្រឡងជ្រើសរើសមន្ត្រីថ្មី និងប្រឡងផ្ទៃក្នុង ធ្វើឡើងក្នុងពេលតែមួយ

-នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ ។

V.**មណ្ឌលប្រឡង**

- វិទ្យាស្ថានព្រះកុសុមៈ ក្រោយវត្តទឹកថ្លា តាមបណ្តោយផ្លូវសហព័ន្ធរុស្ស៊ី ។

**កន្លែងទំនាក់ទំនង ទិញពាក្យនិងដាក់ពាក្យ**នៅទីស្តីការក្រសួង នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក *អាសយដ្ឋាន អគារលេខ៣ មហាវិថី សហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក (ទូរស័ព្ទ ០២៣ ៨៨៤ ៣៧៥)*។ ជិតវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមហាជន និស្សិត មន្ត្រីរាជការដែលមានបំណងចង់ដាក់ពាក្យសុំប្រឡង មេត្តាជ្រាប និងអនុវត្តតាមការគួរ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-គ្រប់ក្រសួង ស្ថាប័ន
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពចំណុះក្រសួង
"ដើម្បីជួយផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ